# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ២០១៦

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 23-Sep-2016, 10:56
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់ នួន ជា អនុលោមតាមវិធាន៨៧(៤)សុំកោះហៅ Patrick Heuveline ជាអ្នកជំនាញប្រជាសាស្ត្រក្នុងសំណុំរឿង០០២/០២ និងសុំឲ្យទទួលយកឯកសារពាក់ព័ន្ធចំនួនពីរជាភស្តុតាង**

---

**ដាក់ដោយ÷**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Victor KOPPE

លីវ សុវណ្ណា

Doreen CHEN

ព្រុំ ផល្លា

Xiaoyang NIE
Marina HAKKOU
Léa KULINOWSKI

ឌី សុជាតា

**ផ្ញើជូន÷**

**សហមេធាវីរបស់ ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

**សហព្រះរាជអាជ្ញា÷**

ជា លាង

Nicholas KOUMJIAN

**សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

## I. សេចក្ដីផ្ដើម

1. អនុលោមតាមវិធាន៨៧(៣), ៨៧(៤) និង ៣១(១០) នៃវិធានផ្ទៃក្នុង សហមេធាវីការពារក្ដីរបស់លោក នួន ជា (“មេធាវីការពារក្ដី”) ស្នើសុំអង្គជំនុំជម្រះសាលាដំបូង៖

(ក) ស្ដាប់សក្ខីកម្មរបស់លោក Patrick Heuveline[1] ជាអ្នកជំនាញទាក់ទងនឹងបញ្ហាចំនួនមនុស្សស្លាប់ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ និងការជំនុំជម្រះលើសំណុំរឿង០០២/០២ វគ្គទាក់ទងនឹងសហករណ៍ ការដ្ឋានធ្វើការងារ ការប្រព្រឹត្តមកលើក្រុមដែលជាគោលដៅ មន្ទីរសន្តិសុខ និង “ការបោសសម្អាតផ្ទៃក្នុង” និង

(ខ) ទទួលយកឯកសារពាក់ព័ន្ធចំនួន ២ ជាភស្តុតាង (“សំណើ”)។

## II. សាវតារ

2. នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំសារណាផ្ទាល់មាត់ស្ដីពីសំណើរបស់ភាគីសុំស្ដាប់សក្ខីកម្មរបស់ Ewa Tabeau[2]។ អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថារបាយការណ៍របស់ Ewa Tabeau មាន “កម្រិតនៃភាពមិនច្បាស់លាស់” នៅពេលនិយាយអំពីបញ្ហា នៃចំនួនការស្លាប់របស់ប្រជាជនចាម និងវៀតណាម[3]។ នៅពេលត្រូវបានទាក់ទងដោយអង្គជំនុំជម្រះសាលាដំបូង Ewa Tabeau បានជូនដំណឹងមកអង្គជំនុំជម្រះថាគ្មានព័ត៌មានស្ថិតិថ្មីទាក់ទងនឹង រយៈកាលរវាងជំរឿនឆ្នាំ ១៩៦២ និងឆ្នាំ ១៩៩៨ ដែលអាចជួយដល់គាត់ក្នុងការផ្ដល់ស្ថិតិ ដ៏ត្រឹមត្រូវជាងនេះ ទាក់ទងចំនួនការស្លាប់របស់ប្រជាជនចាម និងវៀតណាម ចាប់តាំងពីពេលគាត់

---

[1] ដោយហេតុថាមេធាវីការពារក្ដីបានបង្ហាញអត្តសញ្ញាណលោក Heuveline និងចេតនារបស់ខ្លួនក្នុងការស្នើសុំលោក Heuveline ជាសាក្សីអ្នកជំនាញក្នុងសវនាការជាសាធារណៈ មេធាវីការពារក្ដីលើកឡើងថាតម្រូវការការពារអត្តសញ្ញាណសាក្សីអ្នកជំនាញរូបនេះ អស់សុពលភាព និងយោងទៅរកគាត់តាមរយៈឈ្មោះនៅក្នុងសំណើនេះ។

[2] មេធាវីការពារក្ដីកត់សម្គាល់ថា អត្តសញ្ញាណរបស់លោកស្រី Ewa Tabeau ត្រូវបានលើកឡើងជាសាធារណៈនៅក្នុងសវនាការ កាលពីថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ២០១៦ (សូមមើល ប្រតិចារិកសវនាការថ្ងៃទី ១ កញ្ញា ២០១៦ នៅម៉ោង ១០.២២.៤៦ ទំព័រ ៣៦ នៅបន្ទាត់២២ និង ១០.៣១.០៨ ទំព័រ ៤១ បន្ទាត់ទី៥) និង ដែលអង្គជំនុំជម្រះបដិសេធកោះហៅគាត់មកផ្ដល់សក្ខីកម្ម។ អាស្រ័យហេតុនេះហើយមេធាវីការពារក្ដីយល់ថា ខ្លួនអាចនិយាយឈ្មោះគាត់បានដោយមិនចាំបាច់ប្រើរហស្សនាមទៀតនោះទេ។

[3] ឯកសារ E3/2413 “របាយការណ៍អ្នកជំនាញប្រជាសាស្ត្រ, ជនរងគ្រោះខ្មែរក្រហមនៅកម្ពុជា, ខែ មេសា ឆ្នាំ ១៩៧៥-ខែ មករា ឆ្នាំ ១៩៧៩, ការវាយតម្លៃស៊ីជម្រៅលើការប៉ាន់ប្រមាណសំខាន់ៗ” (“របាយការណ៍អ្នកជំនាញប្រជាសាស្ត្រ”), ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៩។

បានចេញរបាយការណ៍របស់គាត់។

3. នៅថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៦ ភាគីបានធ្វើសារណាផ្ទាល់មាត់ស្តីពីបញ្ហានេះ។ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ដោយសារភាពមិនច្បាស់លាស់នៃទិន្នន័យដែលបង្ហាញដោយអង្គជំនុំជម្រះទាក់ទងនឹងចំនួនការស្លាប់ប្រជាជនចាម និងវៀតណាម ដូចនេះគ្មានហេតុផលអ្វីដើម្បីកោះហៅ គាត់ដើម្បីផ្តល់សក្ខីកម្មជាអ្នកជំនាញតទៅទៀតឡើយ។ មេធាវីការពារក្តីក៏បានលើកឡើងថា Ewa Tabeau ពុំគួរត្រូវបានកោះហៅតទៅទៀតឡើយ និងបានកត់សម្គាល់ឃើញថាក្នុងលិខិតរបស់គាត់ជូនចំពោះអង្គជំនុំជម្រះសាលាដំបូង គាត់បានយោងទៅរកអត្ថបទនាពេលថ្មីៗរបស់ Patrick Heuveline ថាជាឯកសារបោះពុម្ពផ្សាយមួយក្នុងចំណោមឯកសារបោះពុម្ពផ្សាយថ្មីៗ ពាក់ព័ន្ធបញ្ហានៃចំនួនការស្លាប់ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ។ មេធាវីការពារក្តីបានកត់សម្គាល់ឃើញបន្ថែមថា Ewa Tabeau បាននិយាយថាគាត់នឹងត្រូវការ "ជាច្រើនខែ"[4] ដើម្បីពិនិត្យ និងវិភាគអត្ថបទនេះ រួមជាមួយសម្ភារៈថ្មីទាំងអស់ ដើម្បីធ្វើបច្ចុប្បន្នភាពរបាយការណ៍របស់គាត់។ មេធាវីការពារក្តីបានគូសបញ្ជាក់ថា Patrick Heuveline ដែលមានកំណត់ត្រាស្រាវជ្រាវទូលំទូលាយ ជាអ្នកប្រជាសាស្ត្រ និងដែលការវិភាគរបស់គាត់ទាក់ទងចំនួនការស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបាន Ewa Tabeau ទទួលស្គាល់ថាជាតួរលេខចុងក្រោយបំផុត គួរត្រូវបានកោះហៅក្នុងនាមជាអ្នកជំនាញជំនួស Ewa Tabeau[5]។

4. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានស្នើសុំឱ្យមេធាវីការពារក្តីដាក់សារណាជាលាយលក្ខណ៍អក្សរដោយបង្ហាញអំពី "អង្គហេតុជាក់លាក់ដែលរៀបរាប់ដោយភស្តុតាងដែលត្រូវបានស្នើឡើង របស់លោក Heuveline និងភាពពាក់ព័ន្ធផ្នែកច្បាប់នៃអង្គហេតុទាំងនោះ"[6] ប្រសិនបើខ្លួនចង់កោះហៅ Patrick Heuveline ជាអ្នកជំនាញ។ នៅថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៦ មេធាវីការពារក្តីបានបញ្ជាក់អះអាងក្នុងអំឡុងសារណាផ្ទាល់មាត់លើបញ្ហាមួយផ្សេង ថាខ្លួនមានបំណងដាក់សំណើបន្ទាន់[7]។ នៅថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានជូន

---

[4] ឯកសារ **E371/2**, "សំណើសុំសេចក្តីសន្និដ្ឋានផ្ទាល់មាត់ស្តីពីសំណើរបស់ភាគីសុំស្តាប់សក្ខីកម្មរបស់ Ewa Tabeau", ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦, ERN 01324584។

[5] ប្រតិចារឹកព្រាង, ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៦ [09.50.14] ដល់ [10.55.43], ទំព័រ ២២-៥៤។

[6] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងទៅភាគី, ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១៦ (**ឯកសារភ្ជាប់១**)។

[7] ប្រតិចារឹកព្រាង, ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៦, ទំព័រ ៥៤ បន្ទាត់ ១១-១៤។

ដំណឹងទៅភាគីថាខ្លួនបានសម្រេចមិនកោះហៅ Ewa Tabeau ដើម្បីផ្តល់សក្ខីកម្មឡើយ[8]។

## III. ច្បាប់ជាធរមាន

### ក. ការកោះហៅអ្នកជំនាញថ្មី

5. គ្រប់ពេលវេលាទាំងអស់ អង្គជំនុំជម្រះសាលាដំបូងត្រូវធានាថាការជំនុំជម្រះមានភាពយុត្តិធម៌ និងឆាប់រហ័ស និងត្រូវបានធ្វើដោយគោរពពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ និងការការពារជនរងគ្រោះ និងសាក្សី។ ជាពិសេស ប្រធានអង្គជំនុំជម្រះត្រូវធានាការអនុវត្តដោយសេរីនូវសិទ្ធិក្នុងការការពារក្តី អនុលោមតាមវិធាន៨៥(១)នៃវិធានផ្ទៃក្នុង។

6. ជនជាប់ចោទម្នាក់ៗនៅចំពោះមុខតុលាការមានសិទ្ធិទទួលបានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់សម្រាប់រៀបចំការពារក្តី ពិនិត្យភស្តុតាងដាក់បន្ទុក និងទទួលបានការបង្ហាញ និងការពិនិត្យភស្តុតាងជំនួសមុខឲ្យពួកគាត់ក្រោមលក្ខខណ្ឌដូចទៅនឹងភស្តុតាងដាក់បន្ទុក។ វាជាកាតព្វកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងដើម្បីការពារសិទ្ធិទាំងនោះ និងធានាថាការជំនុំជម្រះមានភាពយុត្តិធម៌ និងឆាប់រហ័ស និងត្រូវបានធ្វើដោយគោរពពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ និងការការពារជនរងគ្រោះ និងសាក្សី។ ជាពិសេស ប្រធានអង្គជំនុំជម្រះត្រូវធានាការអនុវត្តដោយសេរីនូវសិទ្ធិការពារក្តី[9]។

7. វិធាន៣១(១)នៃវិធានផ្ទៃក្នុងអនុញ្ញាតឲ្យភាគីស្នើសុំឲ្យអង្គជំនុំជម្រះតែងតាំងអ្នកជំនាញបន្ថែម "ដើម្បីធ្វើការពិនិត្យថ្មី ឬពិនិត្យឡើងវិញអំពីបញ្ហាដែលជាកម្មវត្ថុនៃរបាយការណ៍របស់អ្នកជំនាញ" [10]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថាអ្នកជំនាញគឺជា "បុគ្គលដែលមានចំណេះដឹងជំនាញបទពិសោធន៍ ឬជំនាញដែលអាចជួយដល់អង្គជំនុំជម្រះក្នុងការយល់ដឹងទៅលើបញ្ហាវិវាទជាក់

[8] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងទៅភាគី, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦(**ឯកសារភ្ជាប់២**)។

[9] វិធានផ្ទៃក្នុង៨៥(១)។

[10] វិធាន៣១(១០)នៃវិធានផ្ទៃក្នុង។

លាក់ដែលតម្រូវឱ្យមានចំណេះដឹងពិសេសលើវិស័យមួយជាក់លាក់”[11]។

8. វិធាន៨៧(៤) អនុញ្ញាតឱ្យអង្គជំនុំជម្រះកោះហៅបុគ្គលណាម្នាក់ជាសាក្សីដែល “ខ្លួនចាត់ទុកថានាំទៅដល់ការបញ្ជាក់ការពិត” តាមការផ្តួចផ្តើមរបស់ខ្លួន ឬតាមសំណើរបស់ភាគី។ វិធាននេះតម្រូវឱ្យអង្គជំនុំជម្រះពិចារណានៃសំណើ អនុលោមតាមលក្ខខណ្ឌដូចមានចែងក្នុងវិធាន ៨៧(៣)។ ភាគីស្នើសុំត្រូវធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថាសក្ខីកម្មពុំអាចរកបានមុនពេលបើកការជំនុំជម្រះ[12]។ អង្គជំនុំជម្រះបានសម្រេចថា ក្នុងករណីដែលភាពពាក់ព័ន្ធនៃសក្ខីកម្មរបស់បុគ្គលណាម្នាក់ត្រូវបានបង្ហាញប៉ុន្តែដោយ “ព័ត៌មានតិចតួចបំផុត” មុនពេលបើកការជំនុំជម្រះ ទោះជាព័ត៌មានលម្អិតបន្ថែមអាចរកបានក្រោយពេលបើកការជំនុំជម្រះ សក្ខីកម្មដែលចោទជាបញ្ហានឹងត្រូវបានចាត់ទុកថាមិនអាចរកបានមុនពេលបើកការជំនុំជម្រះ[13]។ ក្នុងករណីដែលសក្ខីកម្មអាចរកបានមុនពេលបើកការជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា វាអាចត្រូវបានទទួលយក “ក្នុងករណីដែលផលប្រយោជន៍នៃយុត្តិធម៌តម្រូវដូច្នោះ ពិសេសនៅពេលដែលវាជាភស្តុតាងដោះបន្ទុក និងតម្រូវឱ្យមានការវាយតម្លៃដើម្បីបញ្ចៀសការសម្រេចដោយអយុត្តិធម៌”[14] ឬក្នុងករណីដែលវា“ទាក់ទងជិតស្និទ្ធទៅនឹងសម្ភារៈដែលមានរួចហើយនៅចំពោះមុខអង្គជំនុំជម្រះ និង ... ផលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យវាយតម្លៃប្រភពទាំងនេះជាមួយគ្នា”[15]។ ដើម្បីបំពេញលក្ខខណ្ឌតម្រូវនៃវិធាន

---

[11] ឯកសារ **E367**, “សេចក្តីសម្រេចស្តីពីការតែងតាំងអ្នកជំនាញដែលមានរហស្សនាម 2-TCE-95”, ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥, កថាខណ្ឌ ៧។ *សូមមើល*ផងដែរ ឯកសារ E215 “សេចក្តីសម្រេចលើការចាត់តាំងអ្នកជំនាញ”, ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១២ កថាខណ្ឌ ១៥។

[12] អង្គជំនុំជម្រះបានបញ្ជាក់ថាការបើកសវនាការក្នុងសំណុំរឿង ០០២ គឺជាសវនាការបឋម ដែលបានចាប់ផ្តើមនៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១។

[13] ប្រតិចារឹក, ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ (ការសម្រេចរបស់ អ.ជ.ស.ដ, ឯកសារ **E1/363.1**), ទំព័រ ៤៩ បន្ទាត់ ២-៨។

[14] ឯកសារ **E307/1**, “សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន៨៧(៤) (ឯកសារ E307) និងសេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារ E305/3)”, ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៤, កថាខណ្ឌ ៣។ *ត្រូវនឹង*ឯកសារ E190, “សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត”, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ (“សេចក្តីសម្រេចលើឯកសារថ្មីៗ”), កថាខណ្ឌ ៣៦។

[15] ឯកសារ **E289/2**, “សេចក្តីសម្រេចលើសំណើដោយអនុលោមតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលសុំដាក់ភស្តុតាងថ្មីនៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ **E289**) និងចម្លើយតបរបស់ ខៀវ សំផន (ឯកសារ **E289/1**),” ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣, កថាខណ្ឌ ៣។ *ត្រូវនឹង* ឯកសារ E190, សេចក្តីសម្រេចលើឯកសារថ្មីៗ, កថាខណ្ឌ ៣២។

៨៧(៣) ភស្តុតាងដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងត្រូវការតែភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បានតាមការសន្និដ្ឋានបឋមប៉ុណ្ណោះ[16]។

## ខ. ការទទួលយកឯកសារថ្មី

9. ភស្តុតាងទាំងអស់គឺអាចឲ្យទទួលយកបាន លើកលែងតែមានចែងផ្ទុយពីនេះក្នុងវិធានផ្ទៃក្នុង[17]។ អង្គជំនុំជម្រះអាចបដិសេធសំណើសុំភស្តុតាង ក្នុងករណីដែលខ្លួនយល់ឃើញថាភស្តុតាងនោះ មិនមានភាពពាក់ព័ន្ធ ឬច្រំដែល មិនអាចទទួលបានក្នុងរយៈពេលសមស្រប មិនសមស្របដើម្បីបង្ហាញអង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង មិនត្រូវបានអនុញ្ញាតដោយច្បាប់ ឬប្រសិនបើវាមានចេតនាអូសបន្លាយកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍[18]។ ដើម្បីបំពេញ លក្ខខណ្ឌតម្រូវនៃវិធាន៨៧(៣) ភស្តុតាងដែលត្រូវបានស្នើឡើងត្រូវការភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន*តាមការសន្និដ្ឋានបឋម* ប៉ុណ្ណោះ[19]។ អនុលោមតាមវិធាន៨៧(៤) នៅដំណាក់កាលណាក៏ដោយក្នុងអំឡុងការ ជំនុំជម្រះ ភាគីអាចស្នើសុំឲ្យអង្គជំនុំជម្រះ "ទទួលយកភស្តុតាងថ្មីដែលខ្លួនយល់ថានាំទៅដល់ការ បញ្ជាក់ការពិត" ក្រោមលក្ខខណ្ឌតម្រូវទូទៅនៃវិធាន៨៧(៣)[20]។ បើទោះជាវិធាន៨៧(៤) ចែងថាភស្តុតាងដែលត្រូវបានស្នើសុំត្រូវតែមិនអាចរកបាននៅមុនពេលបើកការជំនុំជម្រះក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកថាវារួមបញ្ចូលភស្តុតាងដែលអាចរកបានមុនពេលបើកការជំនុំជម្រះ ប៉ុន្តែដែលមិនអាចត្រូវបានរកឃើញពីពេលមុននោះ ដោយមានការខិតខំយ៉ាងសមស្រប[21]។

10. ក្នុងកាលៈទេសៈមួយចំនួន ភស្តុតាងដែល "និយាយហួត់ចត់" ពុំបានបំពេញលក្ខខណ្ឌតម្រូវនេះ ត្រូវ

[16] ឯកសារ E313, "សាលក្រមលើសំណុំរឿង ០០២/០១", ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤, កថាខណ្ឌ ២៦។

[17] វិធាន៨៧(១)នៃវិធានផ្ទៃក្នុង។

[18] វិធាន៨៧(៣)នៃវិធានផ្ទៃក្នុង។

[19] ឯកសារ E289/2, "សេចក្តីសម្រេចលើសំណើដោយអនុលោមតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលសុំដាក់ភស្តុតាងថ្មីនៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ E289) និងចម្លើយតបរបស់ ខៀវ សំផន (ឯកសារ E289/1)", ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ២៦ ("សេចក្តីសម្រេចលើសំណើតាមវិធាន៨៧(៤)") ។

[20] *សូមមើល* ប្រតិចារឹកថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ (ព្រំ សារ៉ាត), ឯកសារ E1/382.1), ទំព័រ ២៤, បន្ទាត់ ១១-១៣។

[21] ឯកសារ E313, "សាលក្រមលើសំណុំរឿង ០០២/១", ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤, កថាខណ្ឌ ២៥។ ឯកសារ E289/2, សេចក្តីសម្រេចលើសំណើតាមវិធាន៨៧(៤), កថាខណ្ឌ ៣។

បានទទួលយក៖ ក្នុងករណីដែលភស្តុតាងទាក់ទងជិតស្និទ្ធទៅនឹងសម្ភារៈដែលមានរួចហើយ នៅចំពោះមុខអង្គជំនុំជម្រះ និងក្នុងករណីដែលផលប្រយោជន៍នៃយុត្តិធម៌បានតម្រូវឱ្យវាយតម្លៃ ប្រភពទាំងនោះជាមួយគ្នា ក្នុងករណីដែលភស្តុតាងដែលត្រូវបានស្នើឡើងជាភស្តុតាងដោះបន្ទុក និងបានតម្រូវឱ្យតម្លៃដើម្បីបញ្ចៀសការសម្រេចដោយមិនយុត្តិធម៌ ឬក្នុងករណីដែលភាគីពុំបាន ជំទាស់ទៅនឹងភស្តុតាងនោះ[22]។

## IV. ឧទ្ធរណ៍

### ក. សំណើសុំកោះហៅ *Patrick Heuveline* ជាអ្នកជំនាញ

### *(i) ភាពពាក់ព័ន្ធនៃសក្ខីកម្មរបស់ Patrick Heuveline ទៅនឹងអង្គហេតុក្នុងសំណុំរឿង ០០២/០២*

11. **សារៈសំខាន់នៃបញ្ហាប្រជាសាស្ត្រក្នុងសំណុំរឿង ០០២/០២៖** មេធាវីការពារក្តីលើកឡើងថាប្រជាសាស្ត្រ និងចំនួនការស្លាប់ទូទៅក្នុងអំឡុងយុត្តាធិការពេលវេលានៃតុលាការនេះគឺជាបញ្ហាសំខាន់មួយក្នុងសំណុំរឿង០០២/០២។ ទាំងដីកាដំណោះស្រាយ និងសាលក្រមលើសំណុំរឿង ០០២/០១ បានលើកឡើងអំពីចំនួនមនុស្សស្លាប់ទូទៅដែលមានគុណវុឌ្ឍ[23] ហើយដីកាដំណោះស្រាយក៏បង្ហាញចំនួនមនុស្សស្លាប់សម្រាប់ទីតាំងឧក្រិដ្ឋកម្ម និងវគ្គជាក់លាក់ ដែលត្រូវបានដាក់បញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ជាឧទាហរណ៍មានដូចជា មន្ទីរសន្តិសុខ ស-២១[24] មន្ទីរសន្តិសុខក្រាំងតាចាន់[25] និងការប្រព្រឹត្តិទៅលើប្រជាជនចាម[26] និងវៀតណាម[27]។ ចាប់តាំងពីពេលចាប់ផ្តើមនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ មេធាវីការពារក្តីបានជំទាស់ដាច់ខាតទៅនឹងលទ្ធផលរកឃើញទាំងនោះ។ ជាការពិត មេធាវីការពារក្តីលើកឡើងថាចំនួននៃការស្លាប់ដ៏ត្រឹមត្រូវដែលបំបែកការស្លាប់ ដែលពុំអាចប្រកែកបានចំពោះរបបកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងរយៈកាលពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៧ ខែ មករា ឆ្នាំ ១៩៧៩ តម្រូវឱ្យ

---

[22] ឯកសារ E289/2, សេចក្តីសម្រេចលើសំណើតាមវិធាន៨៧(៤),កថាខណ្ឌ ៣។

[23] ឯកសារ E427, ដីកាដំណោះស្រាយ, កថាខណ្ឌ ១៣៦០ និងសាលក្រមលើសំណុំរឿង ០០២/០១, កថាខណ្ឌ ១៧៤។

[24] ឯកសារ E427, ដីកាដំណោះស្រាយ, កថាខណ្ឌ ៤៦០។

[25] ឯកសារ E427, ដីកាដំណោះស្រាយ, កថាខណ្ឌ ៥១៤។

[26] ឯកសារ E427, ដីកាដំណោះស្រាយ, កថាខណ្ឌ ៧៥៨, ៧៥៩, ៧៨៣។

[27] ឯកសារ E427, ដីកាដំណោះស្រាយ, កថាខណ្ឌ ៧៩២, ៨០២។

មានការពិនិត្យកត្តាជាច្រើនដូចជាយុទ្ធនាការ ទម្លាក់គ្រាប់បែកពីលើអាកាសរបស់សហរដ្ឋអាមេរិក និងសង្គ្រាមស៊ីវិលមុនឆ្នាំ ១៩៧៥ ដែលបាន ញ៉ាំងឲ្យមានស្ថានភាពរស់នៅលំបាកវេទនា ការអត់ឃ្លាន និងរីករាលត្បាតនៃជំងឺ។ មកទល់បច្ចុប្បន្ន ការពិនិត្យដោយយកចិត្តទុកដាក់បែបនេះពុំទាន់ត្រូវបានអនុវត្តក្នុងបរិបទនៃកិច្ចដំណើរការ នីតិវិធីទាំងនេះនៅឡើយទេ។ តាមពិតទៅ មេធាវីការពារក្ដីយល់ថា "ចំនួនមនុស្សស្លាប់ និងការស្លាប់ដោយផ្ទាល់ ការស្លាប់មិនផ្ទាល់ដោយរបបខ្មែរក្រហមគឺវាច្រើនហួស"[28] និងវាពិតជាមិនអាចឈានទៅដល់សេចក្ដីសន្និដ្ឋានសម្រាប់ទូរលេខបានទេ នៅក្នុងការដែលមិនមានជំរឿនជាផ្លូវការនៅកាលបរិច្ឆេទពាក់ព័ន្ធ ឬយ៉ាងហោចណាស់នៅក្បែរកាលបរិច្ឆេទពាក់ព័ន្ធ។

12. សហព្រះរាជអាជ្ញាអន្តរជាតិបាន អះអាងថាលទ្ធផលដែលបានរកឃើញក្នុងផ្នែកប្រជាសាស្ត្រគឺពុំពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់លោក នួន ជា[29]។ ក្រៅពីសារៈសំខាន់ដ៏ចាំបាច់នៃផ្នែកប្រវត្តិនៃសំណុំរឿង មេធាវីការពារក្ដីក៏លើកឡើងថាចំនួនមនុស្សស្លាប់មានផលវិបាកគតិយុត្តិនៅពេលវាយតម្លៃជាឧទាហរណ៍អំពីចេតនារបស់ នួន ជា នៅពេលអនុវត្តគោលនយោបាយជាក់លាក់ណាមួយមាននៅក្នុងពេលនោះ។

13. **ភស្តុតាងរបស់ Patrick Heuveline ស្ដីពីចំនួនមនុស្សស្លាប់ក្នុងអំឡុងយុត្តាធិការពេលវេលា៖** Patrick Heuveline បានបោះពុម្ពផ្សាយអត្ថបទចំនួនបីដែលទាក់ទងនឹងចំនួនមនុស្សស្លាប់ជារួមក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ អត្ថបទចំនួនពីរក្នុងចំណោមអត្ថបទទាំងនោះ ស្ថិតក្នុងសំណុំរឿងរួចហើយ[30] ចំណែកអត្ថបទចុងក្រោយត្រូវបានស្នើសុំឱ្យទទួលយកដោយសហព្រះរាជអាជ្ញា[31]។ ក្នុងអត្ថបទដំបូងចំនួនពីររបស់គាត់ Patrick Heuveline ដោយប្រើប្រាស់គំរូរបស់គាត់

---

[28] ប្រតិចារឹកព្រាង, ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៦, ទំព័រ ២៤ បន្ទាត់ ១៥-១៧។

[29] ប្រតិចារឹកព្រាង, ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៦, [10.27.04] ទំព័រ ៣៩-៤០។

[30] ឯកសារ E3/1798, Patrick Heuveline, "ភាពមិនច្បាស់លាស់នៃការប៉ាន់ស្មានចំនួនមនុស្សស្លាប់នៅសម័យខ្មែរក្រហម", ១៩៩៨។ ឯកសារ E3/1799, Patrick Heuveline, "ចន្លោះពីមួយទៅបីលាននាក់៖ឆ្ពោះទៅកាន់ការស្ថាបនាតួលេខប្រជាសាស្ត្រឡើងវិញក្នុងមួយទសវត្សរ៍នៃប្រវត្តិសាស្ត្រកម្ពុជា (១៩៧០-៧៩)", ១៩៩៨។

[31] ឯកសារ E415, "សំណើរបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៨៧(៤)សុំទទួលយកឯកសារពាក់ព័ន្ធនឹងសក្ខីកម្មរបស់ Michael Vickery និង Henri Locard, ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១៦។ ឯកសារ E415/2.2.2, Patrick Heuveline, "ព្រំដែននៃអំពើប្រល័យពូជសាសន៍៖ ការគណនាភាពមិនពិតប្រាកដនៃចំនួនមនុស្សស្លាប់ក្នុងអំឡុងរបប ប៉ុល ពត នៅកម្ពុជា (១៩៧៥-១៩៧៩)", ២០១៥ ("*ព្រំដែននៃអំពើប្រល័យពូជសាសន៍*")។

នៃ "ការស្តាបនាចំនួនប្រជាសាស្ត្រឡើងវិញ" បានឈានដល់សេចក្តីសន្និដ្ឋានមួយដែលកំហិតត្រឹមការព្យាករណ៍ទូលំទូលាយនូវចំនួនមនុស្សស្លាប់រវាងពី ១,១៧ លាន ទៅ ៣,៤២ លានសម្រាប់រយៈកាលទាំងមូលនៃឆ្នាំ ១៩៧០-៧៩[32]។ ដោយលើកឡើងអំពីភាពស្រពិចស្រពិលរបស់គាត់អំពីរយៈកាលពីឆ្នាំ១៩៧០-៧៥ គាត់ពន្យល់ថា "វិធីសាស្ត្រនៃការកសាងប្រជាសាស្ត្រឡើងវិញពុំអនុញ្ញាតឲ្យយើងវាយតម្លៃអំពីរបាយពេលវេលានៃការសម្លាប់បន្ថែម ក្នុងអំឡុងទសវត្សរ៍នោះ"[33]។ ជាងនេះទៀត Heuveline បានពិនិត្យអំពីការស្លាប់ដ៏ហិង្សាដោយសារកត្តាផ្សេងៗដែលប៉ះពាល់ប្រជាសាស្ត្រកម្ពុជាក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ ដូចជា "ការសម្លាប់រង្គាលប្រឆាំងវៀតណាមក្នុងឆ្នាំ១៩៧០-៧២, [...] ការទម្លាក់គ្រាប់បែករបស់អាមេរិកក្នុងឆ្នាំ ១៩៧៣ និង [...] សង្គ្រាមស៊ីវិលដែលនាំមកនូវជ័យជម្នះរបស់ "ខ្មែរក្រហម"[34]។

14. ក្នុងអត្ថបទចុងក្រោយរបស់គាត់ដែល Ewa Tabeau បានយោងទៅរកក្នុងលិខិតរបស់គាត់ជូនចំពោះអង្គជំនុំជម្រះសាលាដំបូង *The Boundaries of Genocide* , Patrick Heuveline ផ្តល់សេចក្តីសង្ខេបអំពីការព្យាករណ៍មុនៗ ទាក់ទងចំនួនការស្លាប់បន្ថែមក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងពិពណ៌នាអំពីវិធីសាស្ត្រនានាដែលអាចត្រូវបានប្រើដើម្បីទទួលទិន្នន័យប្រជាសាស្ត្រស្តីពីការស្លាប់[35]។ Heuveline ក៏ផ្តល់តារាងមួយដែលសង្ខេបអំពីការព្យាករណ៍ដែលត្រូវបានធ្វើពីពេលមុន រួមទាំងការព្យាករណ៍របស់ Michael Vickery[36] ដែលត្រូវបានតែងតាំងជាអ្នកជំនាញដោយអង្គជំនុំជម្រះសាលាដំបូងប៉ុន្តែបានបដិសេធមិនមកផ្តល់សក្ខីកម្ម[37] និងដែលការប៉ាន់ប្រមានរបស់មជ្ឈមណ្ឌលចារកិច្ចរបស់សហរដ្ឋអាមេរិកច ដែលត្រូវបានធ្វើឡើងនៅឆ្នាំ១៩៨០ ("របាយការណ៍ប្រជាសាស្ត្ររបស់ CIA")[38] ដែលមេធាវីការពារក្តីស្នើសុំឲ្យទទួលយកជាភស្តុតាង[39]។

---

[32] ឯកសារ E3/1799, Patrick Heuveline, "ចន្លោះពីមួយទៅបីលាននាក់៖ ឆ្ពោះទៅកាន់ការស្តាបនាតួលេខប្រជាសាស្ត្រឡើងវិញក្នុងមួយទសវត្សរ៍នៃប្រវត្តិសាស្ត្រកម្ពុជា (១៩៧០-៧៩)", ១៩៩៨ (*"ចន្លោះពីមួយទៅបីលាននាក់"*), ERN 00096731។

[33] ឯកសារ E3/1799, Patrick Heuveline, ចន្លោះពីមួយទៅបីលាននាក់, ERN 00096733-34។

[34] ឯកសារ E3/1799, Patrick Heuveline, *ចន្លោះពីមួយទៅបីលាននាក់*, ERN 00096734។

[35] ឯកសារ E415/2.2.2, Heuveline, *ព្រំដែននៃអំពើប្រល័យពូជសាសន៍*។

[36] ឯកសារ E415/2.2.2, Heuveline, *ព្រំដែននៃអំពើប្រល័យពូជសាសន៍*, ERN 01304754, តារាង ១។

[37] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់នៃអង្គជំនុំជម្រះសាលាដំបូងទៅភាគី, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦ (**ឯកសារភ្ជាប់ ៦**)។

[38] មជ្ឈមណ្ឌលជំរឿងជាតិ អន្តរជាតិ, កម្ពុជា ការអន្តរាយប្រជាសាស្ត្រ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ១៩៨០ ("របាយការណ៍ប្រជាសាស្ត្ររបស់ CIA") **ឯកសារភ្ជាប់ ៥**។

15. Heuveline ចាត់ទុកការព្យាករណ៍របស់ Vickery ថាជា"សមូហកម្មនៃការព្យាករណ៍នានា ដែលការព្យាករណ៍នីមួយៗ មានភាពស្រពិចស្រពិលរបស់វា ដែលពុំត្រូវបានគូសបញ្ជាក់ និងពុំអាចកែប្រែពីឯកសារ ដែលត្រូវបានបោះពុម្ពផ្សាយ[40]។ ជាចុងក្រោយ Heuveline បានរកឃើញថា មានការព្យាករណ៍ ជាមធ្យមមួយថាមានមនុស្សស្លាប់ចំនួន ១,៨០ លាននាក់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[41] ប៉ុន្តែបានសន្និដ្ឋានដោយគូសបញ្ជាក់ថា "ភាពស្រពិចស្រពិលជុំវិញការព្យាករណ៍នានាអំពីចំនួនមនុស្សស្លាប់ក្នុងរបប ប៉ុល ពត គឺមានទំហំធំធេង"[42]។ មេធាវីការពារក្តីសូមជំទាស់ទៅនឹងការលើកឡើងដូចនេះ។

16. មេធាវីការពារក្តីសូមលើកឡើងថា Patrick Heuveline អាចជួយដល់អង្គជំនុំជម្រះ និងភាគីនានា ដើម្បីឱ្យយល់ដឹងអំពីវិធីសាស្ត្រផ្សេងៗដែលអ្នកស្រាវជ្រាវមុនៗ បានប្រើប្រាស់ ដែលពួកគាត់បានឈានដល់ការសន្និដ្ឋានទៅលើទូរលេខបែបចង្អៀត និងក្នុងការវាយតម្លៃទៅលើភាពអាចជឿជាក់នៃលទ្ធផលទាំងអស់នោះ ដោយមិនមានទាំងការស៊ើបអង្កេត បែបកោសល្យវិច័យលម្អិត និងមិនមានទាំងជំរឿនពាក់ព័ន្ធ[43]។ Patrick Heuveline ក៏ប្រហែលអាចជួយបង្ហាញផ្លូវសម្រាប់ចំនួននៃអ្នកស្លាប់ ដែលបានលើកឡើងដោយអ្នកជំនាញផ្សេងៗ សម្រាប់ផ្នែកសវនាការនីមួយៗ នៃសំណុំរឿង00២/0២ ដែលបានបង្ហាញពីខាងលើ។

17. **ភាពពាក់ព័ន្ធនៃសក្ខីកម្មរបស់ Patrick Heuveline ទាក់ទងរបាយការណ៍របស់ Ewa Tabeau ៖** មេធាវីការពារក្តីបានកត់សម្គាល់ថា បើទោះបីជា Ewa Tabeau នឹងមិនត្រូវបានកោះហៅមកផ្តល់សក្ខីកម្ម តែរបាយការណ៍របស់គាត់ ត្រូវបានអង្គជំនុំជម្រះសាលាដំបូង ទទួលយកធ្វើជាភស្តុតាង[44]។ របាយការណ៍នេះត្រូវបានពឹងផ្អែកយ៉ាងច្រើន នៅក្នុងកិច្ចដំណើរការនីតិវិធីសំណុំរឿង 00២។ តាមពិតទៅដីកាដំណោះស្រាយបានពឹងផ្អែកទាំងស្រុង ទៅលើរបាយការណ៍របស់ Ewa

---

[39] សូមមើល កថាខណ្ឌ ២២ដល់ ២៥ខាងលើ។

[40] ឯកសារ E415/2.2.2, ERN 01304754, តារាង ១។

[41] ឯកសារ E415/2.2.2, Heuveline, *ព្រំដែននៃអំពើប្រល័យពូជសាសន៍,* ERN 01304761។

[42] *ដូចឯកសារយោងខាងលើ* ERN 01304764។

[43] *សូមមើលជាឧទាហរណ៍* ប្រតិចារឹកថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ (David CHANDLER), ទំព័រ ៩ ដល់១២។ ប្រតិចារឹកថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣ (François PONCHAUD), ទំព័រ ៧៥ ដល់៧៦។ ឯកសារ **E3/1801,** Bruce Sharp, "រាប់ឋាននរក", ERN 00078288។

[44] ឯកសារ **E3/2413**, "របាយការណ៍អ្នកជំនាញប្រជាសាស្ត្រ"។

Tabeau ក្នុងការសម្រេចថា "ប្រព័ន្ធនេះបានធ្វើឱ្យមនុស្សរាប់លាននាក់ បានក្លាយជាជនរងគ្រោះ ដែលមានចំនួនពី១,៧ ទៅ២,២ លាននាក់ស្លាប់ ដែលក្នុងនោះប្រហែល ៨០០ ០០០ នាក់ស្លាប់ ដោយហឹង្សា"[45]។ អង្គជំនុំជម្រះសាលាដំបូងក៏បានពឹងផ្អែកទៅលើរបាយការណ៍របស់ Ewa Tabeau នៅក្នុងសាលក្រមសំណុំរឿង ០០២/០១ ដែរ[46]។ ហេតុដូច្នេះបើទោះបីជាមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង មិនកោះហៅ Ewa Tabeau ព្រមជាមួយមតិរបស់អង្គជំនុំជម្រះទាក់ទង "កម្រិតនៃភាពមិនប្រាកដប្រជាយ៉ាងច្រើន" នៃលទ្ធផលរបស់គាត់ក៏ដោយ[47] តែជាការសមហេតុផលសម្រាប់មេធាវីការពារក្តីក្នុងការសន្និដ្ឋានថា របាយការណ៍របស់គាត់នឹងប្រើប្រាស់បាន នៅក្នុងសាលក្រមសំណុំរឿង០០២/០២។

18. ដោយគោរពតាមសិទ្ធិរបស់ជនជាប់ចោទ ក្នុងការពិភាក្សាអំពីភស្តុតាងដែលលើកឡើងប្រឆាំងរូបគាត់នោះ មេធាវីការពារក្តីមានសិទ្ធិក្នុងការសួរដេញដោល ទៅលើភស្តុតាងរបស់ Ewa Tabeau ហើយនឹងសួរដេញដោលទៅលើអ្នកជំនាញប្រជាសាស្ត្រដទៃទៀត ដោយប្រើប្រាស់របាយការណ៍របស់គាត់។ អាស្រ័យតាមសំអាងហេតុដូចបានរៀបរាប់ខាងលើ មេធាវីការពារក្តីសូមលើកឡើងថា Patrick Heuveline ដែលត្រូវបានយោងដោយ Ewa Tabeau ថាជាអ្នកសិក្សាដែលបានបោះពុម្ពផ្សាយឯកសារ ស្តីពីចំនួនអ្នកស្លាប់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គឺស្ថិតក្នុងស្ថានភាពដែលល្អបំផុត ដើម្បីមកផ្តល់សក្ខីកម្ម ស្តីពីលទ្ធផលរបស់ Ewa Tabeau ។

***(ii) ភាពអាចជឿជាក់បានរបស់ Patrick Heuveline***

19. ប្រវត្តិរូបរបស់ Patrick Heuveline បង្ហាញពីគុណវុឌ្ឍិផ្នែកសិក្សារបស់គាត់ និងបទពិសោធន៍យ៉ាងទូលំទូលាយរបស់គាត់ ជាអ្នកប្រជាសាស្ត្រ[48]។ តាមពិតទៅ Patrick Heuveline ដែលមានសញ្ញាបត្របណ្ឌិតផ្នែកសង្គមវិទ្យា និងប្រជាសាស្ត្រ បច្ចុប្បន្នគឺជាសាស្ត្រាចារ្យសង្គមវិទ្យា នៅសាកលវិទ្យាល័យ California Los Angeles។ Ewa Tabeau ទទួលស្គាល់ថាគាត់គឺជា "អ្នក

---

[45] ឯកសារ **D427**, ដីកាដំណោះស្រាយ, កថាខណ្ឌ ១៣៦០ និង ជើងទំព័រ ៥២៥៨។

[46] ឯកសារ **E313**, សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ ១៧៣ ដល់១៧៤ និង ជើងទំព័រ ៥២០, ៥២១, ៥២២ និង ៥២៣)។

[47] ឯកសារ **E371/2**, "សំណើរបស់អង្គជំនុំជម្រះសាលាដំបូង សុំឱ្យភាគីធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ ជុំវិញសំណើសុំស្តាប់សក្ខីកម្មលោកស្រីEwa Tabeau", ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦។

[48] ប្រវត្តិរូបសង្ខេបរបស់ Patrick Heuveline (**ឯកសារភ្ជាប់ ៥**)។

ប្រជាសាស្ត្រវែបបវិមាណវិស័យ ដែលមានប្រវត្តិការសិក្សាលេចធ្លោ និងមានការទទួលស្គាល់ជាអន្តរជាតិកម្រិតខ្ពស់"[49]។ តាមពិតទៅសហព្រះរាជអាជ្ញា ស្នើសុំឱ្យទទួលយកធ្វើជាភស្តុតាង នូវអត្ថបទចុងក្រោយរបស់គាត់ ដោយលើកឡើងថា Patrick Heuveline គឺជា "អ្នកជំនាញប្រជាសាស្ត្រដែលត្រូវបានទទួលស្គាល់"[50]។ យោងតាមបទពិសោធន៍របស់គាត់ និងគុណវុឌ្ឍិរបស់គាត់ មេធាវីការពារក្តីសូមលើកឡើងថា Patrick Heuveline បំពេញបានតាមលក្ខខណ្ឌតម្រូវ សម្រាប់ការកោះហៅក្នុងនាមជាអ្នកជំនាញ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

**ខ. សំណើសុំកំណត់កាលបរិច្ឆេទ សម្រាប់ Patrick Heuveline មកផ្តល់សក្ខីកម្មបន្ទាប់ពី (2-TCE-1062)**

20. នៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានអនុញ្ញាត តាមសំណើរបស់មេធាវីការពារក្តីសុំកោះហៅ (2-TCE-1062) មកផ្តល់សក្ខីកម្ម អំពីវិធីសាស្ត្រស្រាវជ្រាវដែលគាត់បានប្រើប្រាស់សម្រាប់ការសិក្សារបស់គាត់ ទៅលើបំណែកអដ្ឋិធាតុដែលរកឃើញនៅជើងឯក[51]។ នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ អង្គជំនុំជម្រះសាលាដំបូង បានជូនដំណឹងដល់ភាគីថា ខ្លួនកំពុងពិចារណាលើការកោះហៅ (2-TCE-1062) ក្នុងនាមជាសាក្សីអ្នកជំនាញ ហើយអញ្ជើញភាគីនានាឱ្យដាក់សារណា ស្តីពីគុណវុឌ្ឍិរបស់គាត់ក្នុងនាមជាសាក្សីអ្នកជំនាញ[52]។ អង្គជំនុំជម្រះមិនទាន់បានកំណត់កាលបរិច្ឆេទ នៃការបង្ហាញខ្លួនរបស់ (2-TCE-1062) ហើយអង្គជំនុំជម្រះក៏មិនទាន់ចេញសេចក្តីសម្រេច ទាក់ទងនឹងឋានៈរបស់គាត់នៅឡើយ។

21. ប្រសិនបើអង្គជំនុំជម្រះអនុញ្ញាតតាមសំណើ សុំកោះហៅ Patrick Heuveline មកផ្តល់សក្ខីកម្ម មេធាវីការពារក្តីសូមស្នើថា គាត់គួរត្រូវបានកោះហៅបន្ទាប់ពី (2-TCE-1062)។ តាមពិតទៅ មេធាវីការពារក្តីសូមលើកឡើងថា Patrick Heuveline ក្នុងនាមជាអ្នកជំនាញផ្នែកប្រជាសាស្ត្រ នឹងអាចផ្តល់នូវការយល់ដឹងដ៏សំខាន់ ជូនអង្គជំនុំជម្រះទាក់ទងសក្ខីកម្មរបស់ (2-TCE-1062) នៅ

---

[49] ឯកសារ **E3/2413**, "របាយការណ៍អ្នកជំនាញប្រជាសាស្ត្រ", ERN 00385248។

[50] ឯកសារ **E415/2**, សំណើរបស់សហព្រះរាជអាជ្ញា តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកឯកសារ ពាក់ព័ន្ធសក្ខីកម្មរបស់ Michael Vickery និង Henri Locard, ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦, កថាខណ្ឌ ៥។

[51] ឯកសារ **E404/4**, អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "សេចក្តីសម្រេចលើការទទួលយកជាឯកសារភស្តុតាង នូវឯកសារសិក្សាពីជើងឯក", ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៦។

[52] ឯកសារ **E404/5**, "2-TCE-1062", ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦, ERN 01321008។

ក្នុងសវនាការ ស្ដីពីវិធីសាស្ត្រស្រាវជ្រាវដែលគាត់ប្រើប្រាស់ សម្រាប់អនុវត្តការសិក្សាអដ្ឋិធាតុនៅជើងឯក។

## គ. **សំណើសុំឱ្យទទួលយកឯកសារពាក់ព័ន្ធចំនួនបីធ្វើជាភស្តុតាង**

### *(i) របាយការណ៍ប្រជាសាស្ត្ររបស់សេអ៊ីអា*

22. **ទិដ្ឋភាពទូទៅនៃឯកសារ៖** ឯកសារដំបូងដែលមេធាវីការពារក្ដី ចង់សុំឱ្យទទួលយកធ្វើជាភស្តុតាង គឺជាឯកសារស្រាវជ្រាវដែលរៀបចំឡើងដោយ the National Foreign Assessment Center of the Central Intelligence Agency សហរដ្ឋអាមេរិក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៨០ ("របាយការណ៍ប្រជាសាស្ត្រសេអ៊ីអា")[53]។ របាយការណ៍នេះពិភាក្សាអំពីទិន្នន័យប្រជាសាស្ត្រដែលមាននៅពេលនោះ ហើយបានផ្ដល់នូវការប្រៀបធៀប ពីចំនួនអ្នកស្លាប់ក្នុងរបប លន់ ណុល របបកម្ពុជាប្រជាធិបតេយ្យ និងការកាន់កាប់ដោយវៀតណាមនៅក្រោយឆ្នាំ១៩៧៩[54]។ ឯកសារនេះបង្កើតបាននូវការវិភាគដំបូងបំផុតមួយ ពីរបបកម្ពុជាប្រជាធិបតេយ្យ ហើយដូចដែលនឹងពន្យល់លម្អិតនៅខាងក្រោម ត្រូវបានពឹងផ្អែកយ៉ាងទូលំទូលាយ នៅក្នុងការផ្សព្វផ្សាយពីប្រជាសាស្ត្រនៅពេលក្រោយមកទៀត[55]។

23. ឯកសារនេះគឺពាក់ព័ន្ធ៖ មេធាវីការពារក្ដីសូមលើកឡើងថា របាយការណ៍ប្រជាសាស្ត្រសេអ៊ីអា គឺទាក់ទងយ៉ាងជិតស្និទ្ធជាមួយ ឯកសារជាច្រើនដែលបង្កើតបានជាផ្នែកនៃសំណុំរឿង ហើយដែលទាក់ទងនឹងការប៉ាន់ប្រមាណ ចំនួនមនុស្សស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងរបាយការណ៍អ្នកជំនាញ Ewa Tabeau[56], សៀវភៅរបស់សាក្សីអ្នកជំនាញ អ៊ីសា ឧស្មាន់[57] ការ

---

[53] National Foreign Assessment Center, Kampuchea: A Demographic Catastrophe, ថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៨០ ('របាយការណ៍ប្រជាសាស្ត្រសេអ៊ីអា')។ (**ឯកសារភ្ជាប់ ៤**)។

[54] របាយការណ៍ប្រជាសាស្ត្រសេអ៊ីអា, ទំព័រ ៤ ដល់៦, (**ឯកសារភ្ជាប់ ៤**)។

[55] ឯកសារ **E3/2413**, "របាយការណ៍អ្នកជំនាញប្រជាសាស្ត្រ", ERN 00385248៖ "របាយការណ៍សេអ៊ីអាឆ្នាំ១៩៨០ គឺជារបាយការណ៍ដំបូងទីមួយ បន្ទាប់ពីខ្មែរក្រហមដួលរលំ ដែលបង្ហាញពីអ្វីដែលហាក់ដូចជារូបភាពដែលលម្អិត និងគួរឱ្យជឿជាក់បានខ្លាំង អំពីប្រជាជនកម្ពុជាចន្លោះឆ្នាំ ១៩៧០ និងឆ្នាំ១៩៧៩"។

[56] ឯកសារ **E3/2413**, "របាយការណ៍អ្នកជំនាញប្រជាសាស្ត្រ"

[57] ឯកសារ **E3/1822**, Ysa Osman, *Oukoubah: Justice of the Cham Muslims under the Democratic Kampuchea Regime*។

បោះពុម្ពផ្សាយរបស់ Ben Kiernan,[58] Bruce Sharp,[59] Craig Etcheson,[60] និង Marek Sliwinski;[61] និងការសិក្សាថ្មីៗពីអដ្ឋិធាតុនៅជើងឯក ដែលដឹកនាំដោយ (2-TCE-1062)[62]។ ជាពិសេសរបាយការណ៍ប្រជាសាស្ត្រសេអ៊ីអា ត្រូវបានយោងនៅសឹងតែគ្រប់ការពិភាក្សាទាំងអស់ទាក់ទងប្រជាសាស្ត្រនៅកម្ពុជា[63] និងត្រូវបាន Michael Vickery ពឹងផ្អែកទៅលើផងដែរ[64]។

24. **ឯកសារអាចពឹងផ្អែកបាន និងមានយថាភាព៖** បន្ថែមលើនេះមេធាវីការពារក្តីយល់ឃើញថា ឯកសារនេះអាចពឹងផ្អែកបានច្រើន។ របាយការណ៍ប្រជាសាស្ត្រសេអ៊ីអា ដូចដែលបានលើកឡើងពីខាងលើ ត្រូវបានរៀបចំឡើងដោយ United States National Foreign Assessment Center ជាសាខារបស់សេអ៊ីអា កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៨០ ហើយត្រូវបាននិយាយយោងនៅក្នុង សឹងតែគ្រប់ការបោះពុម្ពផ្សាយ ដែលនិយាយពីប្រជាសាស្ត្រនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ របាយការណ៍នេះក៏មានព័ត៌មានលម្អិត ស្តីពីវិធីសាស្ត្រស្រាវជ្រាវដែលបានប្រើប្រាស់[65] ដូច្នេះហើយគឺមាននូវគ្រប់ការចង្អុលបង្ហាញទាំងអស់ អំពីយថាភាពនិងភាពអាចជឿជាក់បាន។

25. **ឯកសារនេះចាំបាច់ត្រូវទទួលយកធ្វើជាភស្តុតាង ដើម្បីប្រយោជន៍យុត្តិធម៌៖** សវនាការនៅក្នុងសំណុំរឿង០០២/០២ បានចាប់ផ្តើមនៅខែមិថុនា ឆ្នាំ២០១១។ ទោះបីជារបាយការណ៍ប្រជាសាស្ត្រ

---

[58] **E3/9686**, Ben Kiernan, អំពើប្រល័យពូជសាសន៍ និងការតស៊ូនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

[59] ឯកសារ **E3/1801,** Bruce Sharp, "រាប់ឋាននរក"។

[60] ឯកសារ**E3/1813**, Craig Etcheson បន្ទាប់ពីវាលពិឃាត។

[61] ឯកសារ **E3/1821**, Marck Sliwinski, *Le Génocide Khmer Rouge, une analyse démographique.* ។ M just FYI the differences in the way I formatted the above stuff = difference between books and journal articles/chapters.

[62] ឯកសារ **E404/4/2.2**, "លលាដ៍ក្បាលដោយលលាដ៍ក្បាល, ក្រុមការងារធ្វើបញ្ជីការសម្លាប់ របស់ខ្មែរក្រហម"។ សូមមើលផងដែរ ឯកសារដែលត្រូវបានទទួលយកជាភស្តុតាងនៅក្នុង ឯកសារ **E404/4**, អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "សេចក្តីសម្រេចលើការទទួលយកជាឯកសារភស្តុតាង នូវឯកសារសិក្សាពីជើងឯក", ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៦ ដែលមិនទាន់មានកំណត់លេខបង្ហាញនៅឡើយ។

[63] ឯកសារ **E3/1801,** Bruce Sharp, "រាប់ឋាននរក", ERN 00078267។ ឯកសារ**E3/1813**, Craig Etcheson បន្ទាប់ពីវាលពិឃាត, ERN 00078936; ឯកសារ **E3/2376**, Nayan Chanda, សត្រូវបងប្អូន៖ បន្ទាប់ពីសង្គ្រាមមានសង្គ្រាម, ERN 00192624; ឯកសារ **E3/2413**, "របាយការណ៍អ្នកជំនាញប្រជាសាស្ត្រ", ERN 00385333។ ឯកសារ**E3/3304**, Ben Kiernan, "អំពើប្រល័យពូជសាសន៍ និងប្រជាធិបតេយ្យនៅកម្ពុជា", ERN 00430353.

[64] ឯកសារ **E3/1757**, "ប្រទេសកម្ពុជា ឆ្នាំ១៩៧៥-១៩៨២", Michael Vickery, **ជើងទំព័រ ៩០,** ERN 00397243

[65] របាយការណ៍ប្រជាសាស្ត្រសេអ៊ីអា, ទំព័រ ៦ ដល់៧, (**ឯកសារភ្ជាប់ ៥**)។

សេអ៊ីអា មាននៅមុនពេលចាប់ផ្តើមសវនាការក៏ដោយ មេធាវីការពារក្តីមិនមានបំណងស្នើសុំឱ្យទទួលយកឯកសារនេះឡើយ រហូតដល់ពេលអាចមានវត្តមានរបស់អ្នកជំនាញប្រជាសាស្ត្រ។ ទោះជាក្នុងករណីណាក៏ដោយ របាយការណ៍ប្រជាសាស្ត្រសេអ៊ីអា បានផ្តល់នូវមូលដ្ឋានសម្រាប់ការអះអាងមួយចំនួន ដែលមាននៅក្នុងការបោះពុម្ពផ្សាយ ដែលត្រូវបានទទួលយកទៅក្នុងសំណុំរឿង[66]។ ហេតុដូច្នេះឯកសារនេះពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយ សម្ភារៈដទៃទៀតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលឯកសារនេះចាំបាច់ត្រូវទទួលយក ធ្វើជាភស្តុតាងដើម្បីប្រយោជន៍យុត្តិធម៌ ដើម្បីអាចធ្វើការវាយតម្លៃរួមគ្នា។

*(ii)* ***អត្ថបទរបស់ Patrick Heuveline ស្តីពីចំនួនអ្នកស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ***

26. មេធាវីការពារក្តីស្នើសុំឱ្យទទួលយកធ្វើជាភស្តុតាង នូវអត្ថបទចុងក្រោយបំផុតរបស់ Patrick Heuveline ទាក់ទងចំនួនមនុស្សស្លាប់ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សហព្រះរាជអាជ្ញាក៏បានស្នើសុំឱ្យទទួលយកឯកសារនេះធ្វើជាភស្តុតាងដែរ[67]។ បន្ថែមលើការរៀបរាប់ដែលបានលើកឡើងពីខាងលើ[68] មេធាវីការពារក្តីសូមលើកឡើងថា អត្ថបទរបស់ Patrick Heuveline គឺទាក់ទងជិតស្និទ្ធជាមួយសម្ភារៈ ដែលមានស្រាប់នៅក្នុងសំណុំរឿង និងជាពិសេសការសិក្សាកន្លងមករបស់គាត់ចំនួនពីរ ស្តីពីចំនួនមនុស្សស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[69]។ អត្ថបទនេះនិពន្ធដោយ Patrick Heuveline ដូចដែលបានរៀបរាប់រួចមកហើយ ជាសាស្ត្រាចារ្យសង្គមវិទ្យា និងជាសមាជិក California Center for Population Research នៅក្នុងសាកលវិទ្យាល័យ California Los Angeles[70]។ ហេតុដូច្នេះមេធាវីការពារក្តីសូមលើកឡើងថា ឯកសារនេះគឺអាចជឿជាក់បាន។ ជាចុងក្រោយអត្ថបទនេះត្រូវបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ២០១៥ ដូច្នេះអត្ថបទនេះមិនអាចស្វែង

---

[66] សូមមើលខាងលើ ត្រង់កថាខណ្ឌ ២៥។

[67] ឯកសារ **E415**, សំណើរបស់សហព្រះរាជអាជ្ញា តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកឯកសារ ពាក់ព័ន្ធសក្ខីកម្មរបស់ Michael Vickery និង Henri Locard, ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦។ ឯកសារ **E415/2.2.2**, Heuveline, *The Boundaries of Genocide*។

[68] សូមមើលខាងលើ ត្រង់កថាខណ្ឌ ១៣ ដល់១៤។

[69] ឯកសារ **E3/1798**, Patrick Heuveline, ភាពមិនច្បាស់លាស់នៃការប៉ាន់ស្មាន ចំនួនមនុស្សស្លាប់នៅសម័យខ្មែរក្រហម, ឆ្នាំ ១៩៩៨។ ឯកសារ **E3/1799**, Patrick Heuveline, ចន្លោះពីមួយទៅបីលាននាក់៖ ឆ្ពោះទៅកាន់ការស្ថាបនាតួលេខប្រជាសាស្ត្រឡើងវិញ ក្នុងមួយទសវត្សរ៍នៃប្រវត្តិសាស្ត្រកម្ពុជា (១៩៧០-៧៩), ឆ្នាំ១៩៩៨។

[70] ប្រវត្តិរូបសង្ខេបរបស់ Patrick Heuveline (**ឯកសារភ្ជាប់ ៥**)។

រកបាន នៅមុនពេលចាប់ផ្តើមសវនាការឡើយ។

## V. ដំណោះស្រាយ

27. សម្រាប់សំអាងហេតុដូចបានបញ្ជាក់ពីខាងលើ មេធាវីការពារក្តីសូមស្នើដល់អង្គជំនុំជម្រះសាលាដំបូង៖

ក. កោះហៅ Patrick Heuveline មកផ្តល់សក្ខីកម្ម

ខ. កំណត់កាលបរិច្ឆេទការមកបង្ហាញខ្លួនរបស់ Patrick Heuveline នៅក្រោយ (2-TCE-1062) និង

គ. ទទួលយកជាភស្តុតាងក្នុងសំណុំរឿង ០០២/០២ នូវឯកសារទាំងពីរដូចបានបង្ហាញខាងលើ។

**សហមេធាវីការពារក្តី នួន ជា**

**សុន អរុណ** **Victor KOPPE**